**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអន្តរជាតិនៅផ្សារតូច**
**ថ្ងៃទី០៤ មិថុនា ២០១៧**

អត្ថបទទី១៖ កក ២,១-១១
អត្ថបទទី២៖ ១ករ ១២,៣ខ-៧.១២-១៣
ដំណឹងល្អ៖ យហ ២០,១៩-២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងមានអំណរសប្បាយជួមជុំគ្នា ជាមហាគ្រួសាររបស់ព្រះគ្រីស្តនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅពេលយើងបានស្តាប់បទចម្រៀង អត្ថបទជាភាសាផ្សេងៗពីគ្នា យើងនឹកឃើញដល់ក្រុមគ្រីស្តទូតដែលនិយាយភាសាផ្សេងៗគ្នាដែរ។ សូមស្វាគមន៍លោកឪពុកបងប្អូនទាំងអស់ដែលមកពីសហគមន៍បារាំង កូរ៉េ អង់គ្លេស។

មុនព្រះយេស៊ូឡើងស្ថានបរមសុខ ព្រះយេស៊ូមានព្រះបន្ទូលបីដ៏សំខាន់ជូនដល់ក្រុមគ្រីស្តទូត "**សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត ដូចព្រះបិតាដែលបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំឲ្យអ្នករាល់គ្នាទៅយ៉ាងនោះដែរ ចូរទទួលព្រះវិន័យ**" យើងអាចនិយាយថាព្រះបន្ទូលទាំងបីនេះ ជាលក្ខខណ្ឌដែលព្រះយេស៊ូទុកឲ្យក្រុមគ្រីស្តទូត ដើម្បីបន្តបេសកកម្មដែលព្រះយេស៊ូបានចាប់ផ្តើម។ ព្រះយេស៊ូបានប្រទានសេចក្តីសុខសាន្តឲ្យពួកគេ ដោយសារសេចក្តីសុខសាន្តនេះ ជាសេចក្តីសុខសាន្តមកពីព្រះជាម្ចាស់ ជាមូលដ្ឋានគ្រឹះនៃគ្រប់បេសកកម្មក្នុងជីវិតរបស់យើង។ ប្រសិនបើយើងឥតមានសេចក្តីសុខនៅក្នុងដួងចិត្តយើងមិនអាចកសាងសេចក្តីសុខសាន្តនៅក្នុងពិភពលោក។ ប្រសិនបើយើងឥតមានសេចក្តីសុខនៅក្នុងពិភពលោករបស់យើង ពិភពលោករបស់យើងមិនអាចអភិវឌ្ឍបានទេ។ ប្រសិនបើយើងឥតមានសេចក្តីសុខសាន្តរវាងគ្នានឹងគ្នានៅក្នុងព្រះសហគមន៍ ព្រះសហគមន៍របស់យើងមិនអាចមានជីវិតបានទេ។ ប្រសិនបើយើងត្រឡប់ដល់ថ្ងៃដែលព្រះជាម្ចាស់បានបង្កើតពិភពលោកដំបូង ព្រះជាម្ចាស់បានណែនាំឲ្យពិភពលោកមានសេចក្តីសុខសាន្តនិងសុខដមរមនារវាងគ្នានឹងគ្នាយ៉ាងខ្លាំងបំផុត។ ប៉ុន្តែភ្លាមនោះ អាដាំនិងអេវ៉ា ចាប់ផ្តើមមានចិត្តលោភលន់ មនុស្សចង់ស្មើនឹងព្រះជាម្ចាស់ ដោយបានកសាងកំពូលប៉ាប៊ែល ដើម្បីបង្ហាញថាយើងមានអំណាចលើសព្រះជាម្ចាស់។ ហេតុនេះហើយព្រះជាម្ចាស់ ចង់បង្កើតសុខដមរមនា និងសេចក្តីសុខសាន្តសារជាថ្មី នៅពេលនោះមានទឹកជំនន់ដែលណែនាំឲ្យលិចពិភពលោកទាំងមូល។ បន្ទាប់ពីទឹកបានស្រកចុះបន្តិចម្តងៗ មានសញ្ញាមួយម្តងទៀត

គឺមានព្រាបសបានចេញធ្វើដំណើរពីសំពៅលោកណូអេ នៅពេលត្រលប់មកវិញដើម្បីបង្ហាញថាសេចក្ដីសុខសាន្តត្រលប់មកវិញហើយ។

ពីដើមរៀងមកព្រះជាម្ចាស់បានបង្កើតសេចក្ដីសុខសាន្ត ជាអ្វីដែលពិភពលោករបស់យើងត្រូវការយ៉ាងខ្លាំង។ នៅក្នុងពិភពលោករបស់យើងសព្វថ្ងៃ អ្នកដែលមានអំណាចកំពុងឈ្លោះគ្នាទាក់ទងនឹងការសហការដើម្បីការពារពិភពលោករបស់យើង ការពារថែរក្សាធម្មជាតិ ការពារថែរក្សាអ្វីដែលព្រះជាម្ចាស់ប្រទានឲ្យ ដោយសារពិភពលោកជាផ្ទះរួមរបស់មនុស្ស។ ប៉ុន្មានឆ្នាំថ្នាក់ដឹកនាំទូទាំងពិភពលោក បានចុះហត្ថលេខាឯកភាពគ្នាលើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ឥតលូវត្រូវបែកបាក់ហើយ។ ព្រឹកមិញនៅប្រទេសអង់គ្លេសមានភាវរកម្មដែលកំពុងកើតឡើង ពេលទំនាក់ទំនងរបស់យើងខ្វះសេចក្ដីសុខសាន្ត ដូច្នេះយើងមិនខ្វះការស្អប់គ្នា និយាយដើមគ្នាដើម្បីបង្កើតរឿងដាក់គ្នាទៅវិញទៅមក ទាំងក្នុងសង្គមយើង ទាំងក្នុងព្រះសហគមន៍យើង។

ប៉ុន្តែថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលសម្រាប់យើងយ៉ាងច្បាស់ថា **"សូមសេចក្ដីសុខសាន្តគង់នៅជាមួយបងប្អូន"** ឲ្យយើងទទួលព្រះបន្ទូលនេះ ដើម្បីកសាងជីវិតរបស់យើងផ្ទាល់ខ្លួន ដើម្បីកសាងទំនាក់ទំនងរវាងគ្នានឹងគ្នា។ ដើម្បីកសាងព្រះសហគមន៍ និងពិភពលោក ទីមួយឲ្យយើងយកចិត្តទុកដាក់ថែរក្សាសេចក្ដីសុខសាន្តដែលព្រះជាម្ចាស់ប្រទានមានតែសេចក្ដីសុខសាន្តដែលអាចណែនាំឲ្យជីវិតរបស់យើងរីកចម្រើន ឲ្យពិភពលោករបស់យើងអភិវឌ្ឍយ៉ាងពិតប្រាកដ។ នៅពេលយើងពោរពេញដោយសេចក្ដីសុខសាន្ត នៅពេលនោះព្រះយេស៊ូអាចមានព្រះបន្ទូលដល់យើង **"ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅយ៉ាងនោះដែរ"** នេះជាព្រះបន្ទូលដែលយើងទទួលថ្ងៃនេះ។ ជាពិសេសសម្រាប់បងប្អូនដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាស នេះជាព្រះបន្ទូលសម្រាប់បងប្អូន ព្រះយេស៊ូវចាត់យើងឲ្យយើងទៅប្រកាសដំណឹងល្អដូចព្រះយេស៊ូ។ ព្រះយេស៊ូបានជ្រើសរើសយើងទាំងអស់គ្នា ដើម្បីទទួលបេសកកម្ម ដូចព្រះយេស៊ូបានទទួលបេសកកម្មពីព្រះបិតា។ យើងបន្តបេសកកម្មរបស់ព្រះយេស៊ូ យើងបន្តការប្រកាសដំណឹងល្អនៅលើផែនដីនេះក្នុងជីវិតរបស់យើង។ បងប្អូនត្រូវការគិតពិចារណា អំពីរបៀបដែលយើងត្រូវប្រកាសដំណឹងល្អតទៅទៀត កុំគិតថាយើងត្រូវការប្រកាសដំណឹងល្អនៅក្នុងរបៀបមួយអស្ចារ្យ គឺយើងចាប់ផ្តើមប្រកាសដំណឹងល្អតាមរយៈជីវិតរបស់យើងប្រចាំថ្ងៃ។ នៅក្នុងជីវិតសាមញ្ញ

របស់យើង យើងចេះស្រឡាញ់គ្នាទៅវិញទៅមក ឲ្យយើងចេះបង្ហាញសេចក្តីស្រឡាញ់នៅក្នុងជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងក្រុមគ្រួសារ នៅក្នុងសាលា នៅកន្លែងធ្វើការ។ ធ្វើដូចម្តេច ដើម្បីឲ្យយើងចេះបម្រើគ្នាទៅវិញទៅមក? ពេលព្រះយេស៊ូថា ខ្ញុំចាត់បងប្អូនឲ្យទៅដូចព្រះបិតាបានចាត់ខ្ញុំឲ្យទៅ។ សញ្ញាចុងក្រោយមុនព្រះយេស៊ូសោយទិវង្គត គឺព្រះអង្គបានលាងជើងជូនក្រុមសាវ័ក ដោយមានព្រះបន្ទូលថា **"សូមបម្រើគ្នាទៅវិញទៅមក"** ដូច្នេះសេចក្តីស្រឡាញ់ ជាសេចក្តីស្រឡាញ់ពិតនៅពេលយើងចេះបម្រើគ្នាទៅវិញទៅមក។ ចុងក្រោយ ឲ្យយើងយកចិត្តទុកដាក់លើកលែងទោសឲ្យគ្នាទៅវិញទៅមក គឺលើកលែងទោសយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង ដោយទទួលការលើកលែងទោសពីគេ និងយកចិត្តទុកដាក់លើកលែងទោសដល់គេដែរ។ ដើម្បីបំពេញបេសកកម្មដ៏អស្ចារ្យដែលយើងបានទទួលពីព្រះយេស៊ូ គឺប្រកាសដំណឹងល្អ ប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់តាមរយៈជីវិតរបស់យើងប្រចាំថ្ងៃ។

ព្រះយេស៊ូដឹងថា យើងមិនអាចធ្វើបានដោយកម្លាំងរបស់យើង ទើបព្រះយេស៊ូមានព្រះបន្ទូលថា **"ចូរទទួលព្រះវិញ្ញាណ"** ព្រះយេស៊ូមិនទុកឲ្យយើងឯកោដោយកម្លាំងយើងផ្ទាល់ ដើម្បីស្រឡាញ់ ដើម្បីបម្រើ ដើម្បីលើកលែងទោស ដើម្បីធ្វើជាគំរូដ៏វិសុទ្ធដល់គេ គឺព្រះយេស៊ូបានប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះយេស៊ូប្រទានឲ្យយើង ជាព្រះវិញ្ញាណដ៏វិសុទ្ធដែលណែនាំឲ្យយើងទៅជាធ្លុងតែមួយ ដូចព្រះបិតា ព្រះបុត្រា ជាធ្លុងតែមួយ ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាក្រុមគ្រួសារតែមួយ។ ថ្ងៃនេះនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ យើងទទួលសេចក្តីសុខសាន្តសម្រាប់ព្រះសហគមន៍របស់យើង ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាគ្រួសារមួយ ដែលយល់ថាពិតមែនយើងសប្បាយចិត្តក្នុងការជួមជុំគ្នា ពិតមែនយើងសប្បាយចិត្តអធិដ្ឋានជាមួយគ្នា ពិតមែនយើងជាបងប្អូនបង្កើត។

ឆ្នាំនេះនៅក្នុងភូមិភាគភ្នំពេញ យើងមាន១៥០នាក់ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក យើងមានទាំងយាយចាស់ៗ មានទាំងគ្រូបង្រៀន មានទាំងប្រជាជនធម្មតា មានទាំងកូនង៉ែត មានទាំងយុវជន គេបានទទួលព្រះបន្ទូលនៅក្នុងជីវិតរបស់គេព្រោះគេបានរកឃើញគ្រួសារមួយដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ដែលចេះគោរពគ្នាទៅវិញទៅមក ដែលចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ គ្រួសារដែលចេះស្រឡាញ់គ្នាទៅវិញទៅ

មក គឺជាគ្រួសារដែលចេះទទួលបងប្អូនជានិច្ច ពេលមានបងប្អូនខ្លះដែលវង្វេងផ្លូវ មានបងប្អូនខ្លះទៅឆ្ងាយពីផ្លូវរបស់ព្រះយេស៊ូមិនដឹងខ្លួន ប៉ុន្តែឪពុកម្តាយនៅក្នុងព្រះសហាគមន៍ចេះទទួលស្វាគមន៍ជានិច្ច ដើម្បីលើកលែងទោសឲ្យ។ យើងបានទទួលអំណាចដើម្បោលើកលែងទោសឲ្យគេ ដូចយើងបានស្តាប់ថ្ងៃនេះ "**ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងមានសិទ្ធិលើកលែងទោសឲ្យគេ**"។ នេះជាបទពិសោធន៍សម្រាប់ជីវិតរបស់យើង យើងមានសមត្ថភាពដោយសារព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីលើកលែងទោសឲ្យគេ ដើម្បីបង្កើតគ្រួសារដ៏សុខសាន្តនៅក្នុងព្រះសហាគមន៍។

សូមព្រះវិញ្ញាណដ៏វិសុទ្ធ យាងមកសណ្ឋិតលើព្រះសហាគមន៍ សណ្ឋិតលើពិភពលោក លើសង្គមរបស់យើង ដើម្បីឲ្យយើងរកឃើញសេចក្តីសុខសាន្ត ឲ្យយើងបំផ្លាញការស្អប់គ្នា ការមើលងាយគ្នា ការនិយាយដើមគ្នា ដែលគ្មានប្រយោជន៍សោះ។ ព្រះវិញ្ញាណដ៏វិសុទ្ធសកម្ម ប៉ុន្តែបើយើងមិនសកម្មព្រះវិញ្ញាណដ៏វិសុទ្ធមិនអាចសកម្មបានទេ។ ព្រះវិញ្ញាណដ៏វិសុទ្ធអាចសកម្មប្រសិនបើយើងទទួលពិតមែន ប្រសិនបើយើងខិតខំអនុវត្តពិតមែន។ បម្រើ ស្រឡាញ់ លើកលែងទោស តែបើយើងដេកលក់ យើងបិទត្រចៀក បេះដូង ភ្នែកមើលមិនឃើញ ស្តាប់មិនលឺ ព្រះវិញ្ញាណដ៏វិសុទ្ធមិនអាចសកម្មទេ។ ហេតុនេះហើយថ្ងៃនេះយើងអធិដ្ឋាន ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធមានឥទ្ធិទៅពលលើព្រះសហាគមន៍របស់យើងទៅលើពិភពលោករបស់យើង ដោយដឹងថាអ្វីៗទាំងអស់ អាស្រ័យលើយើងបើកចិត្តគំនិតយើងបើកភ្នែក យើងបើកត្រចៀក ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធមានសកម្មភាពនៅក្នុងពិភពលោក ដើម្បីឲ្យពិភពលោករបស់យើងទទួលសេចក្តីសុខសាន្ត ដូចព្រះយេស៊ូមានព្រះបន្ទូលថា "**សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត**"។ អាម៉ែន។